# ប្រកាស

## ស្តីពី

## ការបង្កើតយន្តការតាមដានឃ្លាំមើល បទល្មើសក្នុងវិស័យព្រៃឈើ និង ការ បំបាត់ភាពអនាធិបតេយ្យ ក្នុងវិស័យ ព្រៃឈើ និងតំបន់ការពារធម្មជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន
លេខ: 429 ប.ស្ត. ប្រក

ក្រសួងបរិស្ថាន
នាយកដ្ឋានការពារ.អភិរក្ស.ធម្មជាតិ
ចូល លេខ..........B.ធ.បណ្ណ
ថ្ងៃទី..17..ខែ..4..ឆ្នាំ..99.

រាជធានីភ្នំពេញ ថ្ងៃទី 24 ខែ 3 ឆ្នាំ ១៩៩9

# ប្រកាស

## ស្តីពីការបង្កើតយន្តការតាមដានឃ្លាំមើល បទល្មើសក្នុងវិស័យព្រៃឈើ និងការបំបាត់ ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ និងតំបន់ការពារធម្មជាតិ

### រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស.រកម .១២៩៦.៣៦ ចុះថ្ងៃទី ធ្នូ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ ប្រក ចុះថ្ងៃទី ២៥ មករា ១៩៩៩ ស្តីអំពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

- បានឃើញសេចក្តីជូនដំណឹង លេខ ២២៨ សជណសរ ចុះថ្ងៃទី ២៣ កុម្ភៈ ឆ្នាំ ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ១:** បង្កើតយន្តការមួយដើម្បីធ្វើការតាមដានឃ្លាំមើលបទល្មើស លើវិស័យព្រៃឈើនៅក្នុង ព្រះរាជាណាចក្រកម្ពុជា មានឈ្មោះថា "ភ្នាក់ងារតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ" ។

**ប្រការ២:** ប្រគល់ភារកិច្ចបន្ថែមជូននាយកដ្ឋានអធិការកិច្ចទទួលអនុវត្តយន្តការនេះរួមមានការតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ និង តំបន់ការពារធម្មជាតិ ។

**ប្រការ៣:** នាយកដ្ឋានអធិការកិច្ចបំពេញមុខងារពង្រីកបន្ថែមដូចតទៅ :

- គ្រប់គ្រង និងកំណត់រោយបានឲ្យស់លាស់ពិពក្រោកជនូវពត៌មានស្តីពី សកម្មភាព អនាធិបតេយ្យ ក្នុង វិស័យ ព្រៃឈើ ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងបរិស្ថានពិនិត្យសំរេច ។
- សហការជាមួយនាយកដ្ឋាននៃក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត-ក្រុង ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ ព្រមទាំង អង្គការក្រៅរដ្ឋាភិបាលក្នុង និង ក្រៅប្រទេស ដើម្បីបានទទួលការទទួលខុសត្រូវចំពោះ តួនាទីរបស់ខ្លួន ។
- ត្រូវធ្វើរបាយការណ៍ជាប្រចាំ ស្តីពីសកម្មភាពរបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថាន ។

**ប្រការ៤:** ទីស្នាក់ការរបស់ភ្នាក់ងារតាមដានឃ្លាំមើលបទល្មើសក្នុងវិស័យព្រៃឈើ នៃក្រសួងបរិស្ថាន ស្ថិតនៅក្នុង តំបន់ការពារធម្មជាតិ ដែលបានប្រកាសដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ។

**ប្រការ៥:** ការរៀបចំផ្ទៃក្នុងនិងការបែងចែកភារកិច្ចនៃភ្នាក់ងារ ដូច មានចែងក្នុងប្រការ ១ ជាសមត្ថកិច្ច របស់ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន ។

**ប្រការ៦ :** មូលនិធិសំរាប់ទ្រទ្រង់ការអនុវត្តន៍ភារកិច្ច តាមដានឃ្លាំមើលបទល្មើស ក្នុងវិស័យព្រៃឈើ ត្រូវបានមកពីថវិការដ្ឋចំណូល ពីប្រភពស្របច្បាប់ផ្សេងៗ និង ជំនួយពី អង្គការអន្តរជាតិនានា ។

<u>ប្រការ៧</u> :ការគ្រប់គ្រង និង ការប្រើប្រាស់មូលនិធិ ក្នុងកិច្ចដំណើរការពោធិ៍ដានឃ្លាំមើលបទល្មើស ក្នុងវិស័យព្រៃឈើត្រូវសំរេច ដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន និង ស្របតាមច្បាប់ហិរញ្ញវត្ថុ ។

<u>ប្រការ៨</u>: អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានអធិការកិច្ច គ្រប់នាយកដ្ឋាន ចំណុះក្រសួងបរិស្ថាន និង មន្ទីរបរិស្ថានខេត្តក្រុង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។ ៨

បណ្ឌិត ម៉ុក-ម៉ារ៉េត

<u>ចំលងជូន</u> :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៨ "ដើម្បីអនុវត្ត"

-ឯកសារ. និងកាលប្បវត្តិ